## របៀបលេងជាមួយនឹងកូនលោកអ្នក

## បង្កើតឲ្យមានការឲ្យតម្លៃដល់ខ្លួនកូនលោកអ្នកនិងជម្រុញឲ្យចេះធ្វើសហប្រតិបត្តិការ

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍



- លេងជាមួយកូនលោកអ្នកឲ្យបានយ៉ាងតិចបំផុត១០ទៅ១៥ នាទីរៀងរាល់ថ្ងៃ។

### ការណែនាំទូទៅសម្រាប់ការលេងជាមួយកូនលោកអ្នក

១. កុំលេងអ្វីដែលជាការប្រណាំងប្រជែង។ ជាពិសេសជាមួយនឹងកូនណាដែលក្មេងជាង។

២. វាជាការប្រសើរជាងក្នុងការលេងប្រដាប់ក្មេងលេងដែលមិនមានទម្រង់ដូចជា ដុំប្លុកជ្រុង(តាមធម្មតា) ឡានត្រាក់ រូបតុក្កតា។ល។

៣. មនុស្សជំទង់ខ្លះៗឃើញថាការនេះជាជំនួយជាច្រើនក្នុងការលេងនៅពេលជាមួយគ្នារាល់ថ្ងៃ។ វិធីយុទ្ធសាស្ត្រមួយទៀតដែលមានប្រយោជន៍គឺដោះទូរស័ព្ទចេញដើម្បីឲ្យកូនក្មេងដឹងថាពេលដែលលោកអ្នកចំណាយជាមួយវាជាពេលសំខាន់។

៤. ប្រសិនបើជាមានកូនក្មេងច្រើនជាងម្នាក់នៅក្នុងគ្រួសារ ចូរព្យាយាមលេងជាមួយនឹងកូនទិមួយដោយឡែកពីគ្នាប្រសិនបើអាចធ្វើទៅបាន។ គឺត្រូវការចំណាយពេលបន្តិចក្នុងការបង្កើតឲ្យមានការប៉ិនប្រសប់ដែលចាំបាច់ក្នុងការលេងទៅវិញទៅមកជាមួយកូនពីរឬច្រើននាក់ឲ្យមានប្រសិទ្ធិភាព ដូច្នេះចូរកុំសាកល្បងធ្វើការនេះទំរាំដល់លោកអ្នកមានការហាត់លេងខ្លះៗជាមួយនឹងកូនទិមួយដោយឡែកពីគ្នាសិន។



©Carolyn Webster-Stratton

# កំណត់សំគាល់សំខាន់ៗ
# អំពីការលេងជាមួយនឹងកូនលោកអ្នក



- ចូរធ្វើតាមគំរូ/ការយល់ថាសំខាន់របស់កូនលោកអ្នក។
- ចូរដាក់ល្បឿនឲ្យស្មើនឹងកូនលោកអ្នក។
- ចូរកុំតម្រូវពីកូនលោកអ្នកហួសហេតុពេក - ទុកពេលវេលាឲ្យវា។
- ចូរកុំប្រជែងជាមួយនឹងកូនលោកអ្នក។
- ចូរសរសើរនិងលើកទឹកចិត្តចំពោះគំនិតនិងការប្រឌិតញាណរបស់កូនលោកអ្នក។ ចូរកុំទិះទានវា។
- ចូរនាំឲ្យកូនលោកអ្នកចាប់ផ្តើមដើរតួលេងពីអ្វីមួយ ហើយធ្វើជាជឿដល់វា។
- ចូរធ្វើជាអ្នកស្តាប់ដែលយកចិត្តទុកដាក់និងអបអរ។
- ចូរធ្វើសេចក្តីសង្កេតដែលជាការពិណនាជាជាងការសួរសំនួរ។
- ចូរបន្ថយចំណង់របស់លោកអ្នកក្នុងការឲ្យជំនួយច្រើនពេក។ លើកទឹកចិត្តកូនលោកអ្នកឲ្យចេះរៀនដោះស្រាយបញ្ហា។
- ចូរឲ្យរង្វាន់ដល់ការលេងដោយស្ងប់ស្ងាត់ដោយផ្តល់ការយកចិត្តទុកដាក់របស់លោកអ្នក។
- ចូរសើចនិងមានការសប្បាយរីករាយ។


© Carolyn Webster-Stratton

## ការជួយកូនលោកអ្នករៀនសូត្រតាមរយៈការលេង

## "ការបង្កើតឲ្យមានការប៉ិនប្រសប់គិតរបស់កូនលោកអ្នក"

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

**អ្វីដែលត្រូវធ្វើ:** 

១. ចូរលេង១០នាទីរាល់ថ្ងៃជាមួយនឹងកូនលោកអ្នកដោយធ្វើនូវសកម្មភាពនៃការសិក្សាដូចជា:

- អានជាមួយគ្នា
- និយាយរឿងមួយប្រាប់គ្នាទៅវិញទៅមក
- លេងល្បែងអ្វីមួយ
- ផាត់ឬលាបពណ៌ជាមួយគ្នា
- លេងរបស់កូនក្មេងលេងផ្សេងៗដែលមិនមានទម្រង់ (ឧទាហរណ៍: ឡូហ្គូ ឆ្នាំងនិងខ្ទះ ដុំប្លុកជ្រុង ស្បៀកពាក់ស្អាតបាត)
- ឆ្លើយនូវសំនួរផ្សេងៗ
- ពិភាក្សាពីកិច្ចការដែលកូនលោកអ្នកកំពុងសម្រេចនិងព្រឹត្តិការណ៍នៅក្នុងកម្មវិធីហ៊ែទ ស្តាត
- លេងជាមួយម៉្សៅលាយទឹកដែលសម្រាប់លេង

នៅពេលអានជាមួយគ្នាលោកអ្នកប្រហែលជាគិតសាកល្បងអានសៀវភៅដែលមិនមានពាក្យនៅក្នុងនោះសោះ - មានតែរូបភាពប៉ុណ្ណោះ!លោកអ្នកនឹងមានការសប្បាយរីករាយក្នុងការប្រឌិតរឿងផ្សេងៗឡើងចេញពីរូបភាពជាមួយនឹងកូនលោកអ្នក។ ប្រសិនបើសៀវភៅនោះមានពាក្យចូរអានឲ្យឮទៅជិតកូនលោកអ្នក។ ចូរហាត់នូវការប៉ិនប្រសប់ដែលយើងបានដាក់ស្នើឲ្យធ្វើនៅក្នុងកម្មវិធីនេះដើម្បីធ្វើឲ្យការទុកចិត្តលើខ្លួនរបស់វាបានចម្រើនឡើង។ សំគាល់មើលពីរបៀបដែលកូនលោកអ្នកឆ្លើយតបចំពោះសេចក្តីខិតខំរបស់លោកអ្នក។

២. ចូរធ្វើសេចក្តីសង្កេតដែលជាការពិណនា និងចូរសរសើរឲ្យបានញឹកញាប់បន្តិចនៅពេលដែលលោកអ្នកលេងជាមួយនឹងកូនលោកអ្នក។ ចូរសង្កេតមើលនូវឥទ្ធិពលអ្វីដែលមានចំពោះកូនលោកអ្នក។


*©Carolyn Webster-Stratton*

[illegible]

# ចំណុចផ្សេងៗដែលត្រូវចងចាំ អំពីការលើកទឹកចិត្តកូនលោកអ្នកឲ្យរៀនសូត្រ



- ចូរបង្ហាញនូវការចាប់អារម្មណ៍យ៉ាងសកម្មនឹងកិច្ចការរបស់កូនលោកអ្នក
- ចូរធ្វើសកម្មភាពសិក្សាជាមួយនឹងកូនលោកអ្នករាល់ថ្ងៃ
- ចូរសរសើរនិងលើកទឹកចិត្តចំពោះសេចក្តីខិតខំដែលតម្រង់ទៅផ្លូវត្រូវរបស់កូនលោកអ្នក (មិនមែនគ្រាន់តែនៅពេលទទួលផលផ្លែទេ)
- ចូររៀបចំឲ្យមានកម្មវិធីផ្តល់រង្វាន់ជាក់ស្តែងបាននៅពេលដែលកូនលោកអ្នកបោះជំហានតូចដើម្បីរៀនពីអ្វីថ្មីមួយ
- ចូរឲ្យមានសេចក្តីសាទរចំពោះកិច្ចការសាលាដែលកូនលោកអ្នកកំពុងសម្រេច
- ចូរធ្វើសហការជាមួយគ្រូព្រមទាំងចូលរួមនឹងពិធីផ្សេងៗនៅសាលារៀន
- ចូរចាប់ផ្តើមធ្វើសកម្មភាពនៃការការសិក្សាដែលស្រួលនិងបង្កើនការធ្វើឲ្យកូនលោកអ្នកខិតខំបន្តិចម្តងៗនៅពេលដែលវាហាក់ដូចជារៀបចំរួចខ្លួនហើយ
- ចូរលោកអ្នកមានសេចក្តីសង្ឃឹមដែលសមហេតុសមផល- ធ្វើតាមការនាំរបស់កូនលោកអ្នកពីអ្វីៗដែលវាមានការរៀបចំខ្លួនជាស្រេចតាមការធំធាត់ឡើងរបស់វា
- ចូរយកចិត្តទុកដាក់យ៉ាងខ្លាំងទៅលើគុណភាពមិនមែនភាពទន់ខ្សោយរបស់កូនលោកអ្នក
- ចូរឲ្យយោបល់ពីអ្វីៗដែលលោកអ្នកពិបាករៀន
- ចូរលើកទឹកចិត្តកូនលោកអ្នកឲ្យចេះរៀនដោះស្រាយបញ្ហា
- ចូរបញ្ចេញឲ្យឃើញពីលក្ខណៈពិតប្រាកដនៃសមត្ថភាពរបស់កូនលោកអ្នកនៅពេលអនាគត


*©Carolyn Webster-Stratton*



## កំណត់សំគាល់សំខាន់ៗ

# ចំណុចផ្សេងៗដែលត្រូវចងចាំ
# អំពីការបង្កើតឲ្យមានការឲ្យតម្លៃដល់ខ្លួនកូនលោកអ្នក

- ចូរឲ្យតម្លៃនិងយកចិត្តទុកដាក់របស់លោកអ្នកទាំងស្រុងទៅលើការលេងរបស់កូនលោកអ្នក
- ចូរស្តាប់កូនលោកអ្នក --ចូរឃ្លាំមើលនៅពេលដែលកូនលោកអ្នកចំហចិត្តចង់និយាយ ចូរកុំបង្ខំវាឲ្យនិយាយប្រសិនបើវាមិនចង់
- ចូរពង្រឹងសេចក្តីខិតខំរៀនសូត្ររបស់កូនលោកអ្នកដោយពិពិណនាអំពីអ្វីដែលវាកំពុងធ្វើ
- ចូរសរសើរពីសេចក្តីខិតខំរបស់កូនលោកអ្នកនិងជោគជ័យរបស់វាដែរ
- **នៅពេលអាន:**

  **ចូរសួរនូវសំនួរដែលស្រួលៗ**
  **ចូរចៀសវាងការបញ្ជានិងការកែប្រដៅ**
  **ចូរស្ម័គ្រចិត្តជួយនៅពេលណាដែលមានការសុំឲ្យជួយតែប៉ុណ្ណោះ**
- ចូរបង្កើតឲ្យមានឱកាសសម្រាប់ឲ្យកូនលោកអ្នកនិយាយរឿងដែលវាបានទន្ទេញចាំសារឡើងវិញ
- លើកទឹកចិត្តកូនលោកអ្នកឲ្យសរសេររឿងវាដោយខ្លួនឯងឬឲ្យវាហៅឲ្យលោកអ្នកសរសេរ
- ចូរអានឲ្យកូនលោកអ្នកស្តាប់ឲ្យបានញឹកញាប់ព្រមទាំងអនុញ្ញាតឲ្យវាមើលលោកអ្នកអាន
- ចូរលើកទឹកចិត្តកូនលោកអ្នកប្រឌិតរឿងផ្សេងៗព្រមទាំងដើរតួរលេងពីរឿងនោះ


*©Carolyn Webster-Stratton*



# ការចាត់ឲ្យទៅធ្វើដំណើរដើម្បីសិក្សា

A. នៅពេលខ្លះៗនៅក្នុងបីសប្តាហ៍ខាងមុខនេះលោកអ្នកមានការចាត់ឲ្យទៅកន្លែងផ្សេងៗដើម្បីមើលសិក្សាដើម្បីធ្វើឲ្យបានសកម្មភាពមួយយ៉ាងតិចបំផុតក្នុងចំណោមសកម្មភាពដែលមាននៅខាងក្រោមនេះ:

- ចូរទៅបណ្ណាល័យនៅក្នុងតំបន់លោកអ្នកជាមួយនឹងកូនលោកអ្នក។ ចូរនិយាយជាមួយនឹងបណ្ណារក្សពីសៀវភៅផ្សេងៗដែលជាការគួរឲ្យមានការចាប់អារម្មណ៍សម្រាប់កូនលោកអ្នកព្រមទាំងសួរកូនលោកអ្នកឲ្យរើសយកសៀវភៅបីបួន។

**និង/ឬ**

- ចូរទៅថ្នាក់រៀនហើទស្កាតរបស់កូនលោកអ្នកព្រមទាំងចំណាយពេលលេងជាមួយកូនលោកអ្នកនៅក្នុងបន្ទប់ថ្នាក់រៀននោះ។ ចូរនិយាយជាមួយនឹងគ្រូបង្រៀនរបស់កូនលោកអ្នកពីរបៀបកូនលោកអ្នករៀនសូត្រ។ ចូរផ្តល់នូវការអានឬជំនួយនៅក្នុងថ្នាក់(ឬនៅពេលធ្វើដំណើរទៅកន្លែងមួយដើម្បីសិក្សា)។ ចូរឲ្យបានស្គាល់នូវកម្មវិធីនិងទម្រង់ការសិក្សារបស់កូនលោកអ្នក។

B. ចូរសរសេរទុកនូវអ្វីៗដែលលោកអ្នកបានធ្វើនិងពីរបៀបដែលលោកអ្នកគិតពីការពិសោធន៍នៅលើទំព័រដែលដាក់ថា" Field Notes" ("ការកត់សំគាល់ពីការធ្វើដំណើរសិក្សា")។



*©Carolyn Webster-Stratton*

# របៀបសរសើរនិងលើកទឹកចិត្តកូនលោកអ្នកដែលមានប្រសិទ្ធិភាព

## "បញ្ចេញឲ្យឃើញនូវអ្វីដែលប្រសើរបំផុតនៃកូនលោកអ្នក"

## សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

**អ្វីដែលត្រូវធ្វើ:** 

- **ចូរបន្តការលេង** (និងការអាន) ជាមួយនឹងកូនលោកអ្នករាល់ថ្ងៃឲ្យបានយ៉ាងហោចណាស់១០នាទី។
- **ចូរហាត់ប្រើ** ពាក្យសរសើរនៅពេលកំពុងលេង។
- **ជ្រើសរើសយកអាកប្បកិរិយាមួយ** ដែលលោកអ្នកចង់នាំឲ្យកូនលោកអ្នកចាប់ផ្តើមធ្វើឲ្យបានកាន់តែញឹកញាប់និងមានរបៀប។ សរសើរវានៅពេលដែលវាប្រកាន់អាកប្បកិរិយានោះនៅសប្តាហ៍ក្រោយៗ: ឧទាហរណ៍: លេងដោយស្ងប់ស្ងាត់ ទៅគេងនៅពេលដែលប្រាប់ឲ្យទៅ រើសយកប្រដាប់ប្រដារលេងទុក និងឲ្យអ្នកឯទៀតលេងជាមួយដែរ។
- **ចូរបង្កើននូវចំនួននៃការសរសើរ** ដែលលោកអ្នកឲ្យនិងសង្កេតមើលនូវឥទ្ធិពលអ្វីដែលមានទៅលើកូនលោកអ្នក។
- **សរសេរជាតារាង** ពីអាកប្បកិរិយាណាៗខ្លះដែលលោកអ្នកចង់ឃើញថែមទៀតនៅលើក្រដាស់ Behavior Record (បញ្ជីសម្រាប់កត់ពីអាកប្បកិរិយា)ដែលគេចែកឲ្យលោកអ្នក។
- ចូរទូរស័ព្ទទៅសំឡាញ់លោកអ្នកដែលនៅក្នុងក្រុមនោះ។

## ការប្រើកម្មវិធីឲ្យរង្វាន់ជាក់ស្តែងដើម្បីបង្រៀនពីអាកប្បកិរិយាថ្មីៗដល់កូនលោកអ្នក

## "ធ្វើឲ្យកូនលោកអ្នកចង់ធ្វើអ្វីមួយដោយបង្ហាញឲ្យឃើញនូវហេតុផល"

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

**អ្វីដែលត្រូវធ្វើ:** 

- ចូរបន្តការលេង (និងការអាន) ជាមួយនឹងកូនលោកអ្នករាល់ថ្ងៃឲ្យបានយ៉ាងហោចណាស់១០នាទី។ និង ចូរបង្កើនទូវចំនួននៃការសរសើរ ដែលលោកអ្នកឲ្យទៅកូនលោកអ្នក។
- ពីតារាងបញ្ជីនៃអាកប្បកិរិយាដែលលោកអ្នកចង់ឃើញថែមទៀត(នៅលើក្រដាស់បញ្ជីសម្រាប់កត់ពីអាកប្បកិរិយាដែលគេចែកឲ្យលោកអ្នក។ ជ្រើសរកអាកប្បកិរិយាមួយមករៀនអនុវត្តន៍ដោយប្រើរបៀបដែលមានការកត់លើតារាងជាការសង្កេតមើលការរីកចម្រើនឬឲ្យស្ទីគ្គឺ(ស្លាកបិទ)។
- ចូរពន្យល់ពី របៀបប្រើរូបផ្កាយនិងការកត់លើតារាងជាការសង្កេតមើលការរីកចម្រើនដល់កូនលោកអ្នកដើម្បីលើកទឹកចិត្តវាឲ្យធ្វើអាកប្បកិរិយាណាដែលលោកអ្នកចង់ឲ្យវាធ្វើ។ ធ្វើ ការកត់លើតារាងជាការសង្កេតមើលការរីកចម្រើនព្រមទាំងយក តារាងនោះមកពេលប្រជុំលើកក្រោយ។
- ទូរស័ព្ទទៅសំឡាញ់លោកអ្នកដែលនៅក្នុងក្រុមនោះព្រមទាំងចែកប្រាប់ឲ្យគេដឹងពីគំនិតនៃការឲ្យរង្វាន់របស់លោកអ្នក។



*©Carolyn Webster-Stratton*



# ចំណុចត្រូវចងចាំ
# អំពីការប្រើរង្វាន់

- ចូរឲ្យអត្ថន័យនៃអាកប្បកិរិយាត្រឹមត្រូវរបស់កូនក្មេងឲ្យបានច្បាស់លាស់។ ចូរធ្វើឲ្យជំហាននោះតូច។
- ចូរបង្កើនឲ្យមានការខំប្រឹងប្រែងបន្តិចម្តងៗ។
- ចូរកុំធ្វើឲ្យកម្មវិធីនោះពិបាកពេក-ជ្រើសរើសយកអាកប្បកិរិយាមួយឬពីរដើម្បីយកមកចាប់ផ្តើមអនុវត្តន៍។
- ចូរយកចិត្តទុកដាក់ខ្លាំងទៅលើអាកប្បកិរិយាដែលធ្វើឲ្យមានការស្ញប់ស្ញែង។
- ចូរជ្រើសរើសយករង្វាន់ដែលមិនថ្លៃ។
- ចូរឲ្យមានរង្វាន់ប្រចាំថ្ងៃ។
- ចូរឲ្យកូនលោកអ្នកចូលរួមនៅក្នុងការជ្រើសរើសយករង្វាន់។
- ចូរយកអាកប្បកិរិយាត្រឹមត្រូវជាមុនសិន *ទើប*ឲ្យរង្វាន់។
- ចូរឲ្យរង្វាន់ដល់ជោគជ័យប្រចាំរៀងរាល់ថ្ងៃ។
- ចូរឲ្យនូវការអ្វីជាការយល់ព្រមនៅក្នុងសង្គមជំនួសរង្វាន់បន្តិចម្តងៗ។
- ចូរឲ្យបានការច្បាស់និងជាក់លាក់អំពីរង្វាន់។
- ចូរឲ្យមានបញ្ជីរាយមុខនៃរង្វាន់ផ្សេងៗពីគ្នា។
- ចូរបង្ហាញកូនលោកអ្នកថាលោកអ្នកស្ញប់ស្ញែងឲ្យមានជោគជ័យ។
- ចូរកុំដាក់រង្វាន់លាយឡំនឹងទណ្ឌកម្ម។
- ចូរត្រួតពិនិត្យមើលកម្មវិធីឲ្យរង្វាន់ឲ្យបានជាប់លាប់។


©Carolyn Webster-Stratton

# ការដាក់កម្រិតដែលមានប្រសិទ្ធិភាព

## សេចក្តីសំខាន់នៃការច្បាស់លាស់ ការដែលអាចទាយទុកជាមុនបាន និងការដែលប្រកបដោយសេចក្តីសង្ឃឹម

## សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

### អ្វីដែលត្រូវធ្វើ:



- **ចូរបន្ថយ** ចំនួននៃការបញ្ជាដែលលោកអ្នកឲ្យទៅទរណាដែលសំខាន់ជាងគេបំផុត។
- នៅពេលណាដែលចាំបាច់ **ចូរឲ្យបញ្ជាដែលប្រកបដោយសេចក្តីសង្ឃឹមនិងជាក់លាក់។** ចូរចៀសវាងប្រើសំនួរដែលជាការបញ្ជាដូចជាពាក្យបញ្ជា "ទុកឲ្យយើង" សេចក្តីបញ្ជាដែលជាការបដិសេធ សេចក្តីបញ្ជាដែលមិនច្បាស់លាស់និងសេចក្តីបញ្ជាដែលជាសេចក្តីបញ្ជាបន្ត។
- **ចូរហាត់ប្រើពាក្យបញ្ជា "នៅពេល/បន្ទាប់មក"។**
- **ចូរសរសើរ** កូនលោកអ្នកនៅរាល់ពេលដែលវាធ្វើតាមសេចក្តីបញ្ជាមួយ។
- ចូរប្រើក្រដាសដែលនិយាយពីវិន័យនៅក្នុងផ្ទះដែលគេចែកឲ្យដើម្បីយកមកប្រើជាវិន័យខ្លះៗដែលលោកអ្នកយល់ថាសំខាន់ជាងគេ។ ចូរសរសេរទុកនៅលើក្រដាសដែលនិយាយពីវិន័យនៅក្នុងផ្ទះដែលគេចែកឲ្យហើយយកបញ្ជីនោះមកពេលប្រជុំនៅលើកក្រោយ។
- ចូរទូរស័ព្ទទៅសំឡាញ់លោកអ្នកដែលនៅក្នុងក្រុមនោះព្រមទាំងនិយាយពីវិន័យនៅក្នុងផ្ទះផ្សេងៗ។

***Caution: Remember to continue playing!***

 *©Carolyn Webster-Stratton*



# កំណត់សំគាល់សំខាន់ៗ
# អំពីរការដាក់កម្រិត

- ចូរកុំឲ្យសេចក្តីបញ្ជាដែលមិនមែនជាការចាំបាច់។
- ចូរឲ្យសេចក្តីបញ្ជាម្តងមួយៗ។
- ចូរឲ្យសេចក្តីសង្ឃឹមរបស់លោកអ្នកសមហេតុសមផលនិងប្រើពាក្យបញ្ជាដែលត្រឹមត្រូវតាមអាយុ។
- ចូរប្រើពាក្យបញ្ជា"ចូរធ្វើ"។
- ដាក់សេចក្តីបញ្ជាដែលជាសេចក្តីសង្ឃឹមនិងមានការគួរសម។
- ចូរកុំប្រើពាក្យបញ្ជា"ឈប់"។
- ចូរឲ្យឱកាសដល់កូនក្មេងឲ្យបានគ្រប់គ្រាន់ដើម្បីធ្វើតាម។
- ចូរឲ្យសេចក្តីប្រមាននិងសេចក្តីរំលិកដែលមានប្រយោជន៍។
- ចូរកុំគំរាមគំហែងកូនក្មេង: ចូរប្រើពាក្យបញ្ជា"នៅពេល-បន្ទាប់មក"។
- ចូរឲ្យអំណាចនឹងរើសដល់កូនក្មេងនៅពេលណាដែលអាចធ្វើទៅបាន។
- ចូរធ្វើសេចក្តីបញ្ជាឲ្យបានខ្លីនិងចំចំណុច។


*©Carolyn Webster-Stratton*

## របៀបដើរតាមមើលកម្រិតនិងវិន័យផ្សេងៗឲ្យចប់

## " វិធីអប់រំកុមារដែលមានអាកប្បកិរិយាដែលជាការមិនស្តាប់បង្គាប់និងការ វាយតប់ឬបំផ្លេចបំផ្លាញ"

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

### អ្វីដែលត្រូវធ្វើ:



- **ចូរបន្ថយ** ចំនួននៃការបញ្ជាដែលលោកអ្នកឲ្យទៅនរណាដែលសំខាន់ជាងគេបំផុតតទៅទៀត។ ឲ្យសេចក្តីបញ្ជានៅពេលណាដែលលោកអ្នករៀបចំខ្លួនដើរតាមមើលឲ្យចប់។
- **ចូរធ្វើព្រងើយកន្តើយ** នឹងការឆ្លើយតបដែលមិនត្រឹមត្រូវនឹងសេចក្តីបញ្ជា។
- ចូរចៀសវាងការជជែកឈ្លោះជាមួយនឹងកូនលោកអ្នកពីរឿងវិន័យនិងសេចក្តីបញ្ជា។ ចូរព្យាយាមប្រើអ្វីដែលធ្វើឲ្យរំខានឬបង្វែឲ្យដោះស្រាយបន្ទាប់ពីលោកអ្នកបានប្រាប់កូនលោកអ្នកថាវាមិនអាចធ្វើអ្វីមួយបាន។
- ចូរសរសើរកូនលោកអ្នកដោយវាបានធ្វើតាមសេចក្តីបញ្ជារបស់លោកអ្នក(ឬក៏រៀបចំកម្មវិធីពង្រឹងឲ្យធ្វើតាម)។
- ចូររើសយកកន្លែងមួយដែលត្រឹមត្រូវហើយសុខសម្រាប់ដាក់កុមារនៅពេលដាក់ទណ្ឌកម្មឲ្យនៅតែឯង។
- ចូរពន្យល់កូនលោកអ្នកពីរបៀបដែលពេលដាក់ជាទណ្ឌកម្មឲ្យនៅតែឯងនឹងត្រូវដើរនិងពេលយកវាមកប្រើ (ឧទាហរណ៍: នៅពេលប្រកាន់អាកប្បកិរិយាដែលធ្វើឲ្យមានការវាយតប់និងបំផ្លេចបំផ្លាញ")
- ធ្វើជាតារាងបញ្ជីពីអាកប្បកិរិយាដែលលោកអ្នកចង់ឃើញតិចតួចនៅលើក្រដាសសម្រាប់កត់ពីអាកប្បកិរិយាដែលគេចែកឲ្យ។
- ចូរទូរស័ព្ទទៅសំឡាញ់លោកអ្នកដែលនៅក្នុងក្រុមនោះព្រមទាំងចែកនូវគំនិតពីពេលដាកទណ្ឌកម្មឲ្យនៅតែឯងផង។

### ចូរអាន:

- ក្រដាសដែលគេចែកឲ្យ

# កំណត់សំគាល់សំខាន់ៗ
# អំពីរការធ្វើមិនអើពើដឹង




- ចូរចៀសវាងការមើលឲ្យចំនឹងភ្នែកនិងការពិភាក្សានៅពេលធ្វើការមិនអើពើដឹង។
- ចូរដកខ្លួនលោកអ្នកចេញឲ្យឆ្ងាយពីកូនលោកអ្នកក៏ប៉ុន្តែនៅក្នុងបន្ទប់ជាមួយគ្នាប្រសិនបើអាចធ្វើទៅបាន។
- ចូរឲ្យមានការប្រសប់ពីរបៀបដែលលោកអ្នកធ្វើមិនអើពើដឹង។
- ចូរប្រុងប្រៀបជាមុនសម្រាប់ការធ្វើការពិសោធន៍។
- ចូរធ្វើឲ្យបានជាប់លាប់។
- ចូរយកចិត្តទុកដាក់ឡើងវិញនៅពេលដែលកូនលោកអ្នកឈប់ធ្វើអាកប្បកិរិយាមិនត្រឹមត្រូវ។
- ចូរដាក់ការនាំឲ្យរំខាននិងការធ្វើមិនអើពើដឹងជាមួយគ្នា។
- ជ្រើសរើសយកអាកប្បកិរិយាជាក់លាក់មួយដែលលោកអ្នចង់ធ្វើមិនអើពើដឹងហើយត្រូវដឹងច្បាស់ថាអាកប្បកិរិយានោះហើយដែលលោកអ្នកអាចធ្វើមិនអើពើដឹងបាន។
- ចូរដាក់កម្រិតដែលមានរបៀបលើចំនួនអាកប្បកិរិយាដើម្បីធ្វើមិនអើពើដឹង។
- ចូរយកចិត្តទុកដាក់ទៅលើអាកប្បកិរិយាល្អរបស់កូនលោកអ្នក។

 *©Carolyn Webster-Stratton*

# របៀបបន្ថយអាកប្បកិរិយាមិនត្រឹមត្រូវរបស់កូនលោកអ្នក

## " ការធ្វើមិនអើពើដឹង ផលវិបាក និង ការដោះស្រាយបញ្ហា"

## សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

### អ្វីដែលត្រូវធ្វើ: 

ជ្រើសរើសយកអាកប្បកិរិយាមិនត្រឹមត្រូវជាក់លាក់មួយ យកមកអនុវត្តន៍ដោយប្រើការដាក់ទណ្ឌកម្មឲ្យនៅតែឯង: ជាឧទាហរណ៍ ដូចជាការឈ្លោះឬវាយតប់គ្នា។ ចូរសរសេរនៅលើសន្លឹកក្រដាសសម្រាប់" កត់ទុកជាឯកសារពីសេចក្តីបញ្ជានិងការដាក់ទណ្ឌកម្មឲ្យនៅតែឯង" ("Record Sheet: Commands and Time Out ")។

- ជ្រើសរកអាកប្បកិរិយាមិនល្អមួយចេញពីតារាងបញ្ជីនៃអាកប្បកិរិយាដែលលោកអ្នកចង់ឃើញតិចជាង ជាឧទាហរណ៍ការមោយាឬនិយាយចំអេសចំអាស) និង ហាត់ធ្វើមិនអើពើដឹង នឹងអកប្បកិរិយានិមួយនោះដែលកើតឡើងនៅក្នុងអាទិត្យនោះ។

- ចំពោះអាកប្បកិរិយាមិនល្អដែលលោកអ្នកសរសេរដាក់នៅក្នុងលេខ២នៅខាងលើចូរគិតពីពាក្យផ្ទុយនឹងពាក្យនោះ។ ជាឧទាហរណ៍ពាក្យផ្ទុយនឹងពាក្យស្រែកគំហកគឺនិយាយល្អនិងពាក្យផ្ទុយនឹងពាក្យកញ្ឆក់ប្រដាប់ប្រដាលេងពីអ្នកឯទៀតគឺចែកឲ្យគេលេងដែរ។ ដូច្នេះចូរសរសើរអាកប្បកិរិយាដែលផ្ទុយនេះឲ្យមានជារបៀបនៅរាល់ពេលណាដែលការនេះកើតឡើងនៅក្នុងអាទិត្យនោះ។

## ការអបអរនិងការដើរទៅមុខទៀត!

- ចូរគិតពីផ្លូវផ្សេងៗដែលលោកអ្នកអាចបន្តទទួលការទ្រទ្រង់ដល់ការខិតខំដឹកនាំចិញ្ចឹមកូនចៅ។

- ចូរយកគំនិតផ្សេងៗរបស់លោកអ្នកទៅពេលប្រជុំនៅពេលក្រោយ។

 *©Carolyn Webster-Stratton*




# កំណត់សំគាល់សំខាន់ៗ
# អំពីរការដាក់ទណ្ឌកម្មឲ្យនៅតែឯង

- ចូរឲ្យមានការគួរសម។
- ចូរប្រុងប្រៀបធ្វើការពិសោធន៍។
- ចូរត្រួតត្រាពិនិត្យមើលកំហឹងដើម្បីចៀសវាង ការផ្ទុះភ្នាម។ ចូរឲ្យសេចក្ដីប្រមាន។
- ចូរដាក់ទណ្ឌកម្មឲ្យនៅតែឯង៥នាទីដោយទុកឲ្យមានការស្ងប់ស្ងាត់នៅពេល២នាទីចុងក្រោយ។
- ចូរប្រយ័ត្ននៅក្នុងការដាក់កម្រិតចំនួននៃអាកប្បកិរិយាដែលត្រូវទទួលការដាក់ទណ្ឌកម្មឲ្យនៅតែឯងជាព្រមទាំងប្រើចំនួននោះឲ្យបានទៀងទាត់។
- ចូរប្រើការដាក់ទណ្ឌកម្មឲ្យនៅតែឯងឲ្យបានជាប់លាប់ចំពោះអាកប្បកិរិយាដែលមិនត្រឹមត្រូវ។
- ចូរកុំគំរាមកំហែងប្រើការដាក់ទណ្ឌកម្មឲ្យនៅតែឯងលុះណាតែលោកអ្នកប្រុងប្រៀបដើរតាមធ្វើឲ្យចប់។
- ចូរធ្វើប្រងើយកន្ដើយនឹងកុមារនៅពេលដែលគេវាដាក់ទណ្ឌកម្មឲ្យនៅតែឯង។
- ចូរប្រើវិធីដែលមិនខ្លាំងដូចជាដកយកការទុញ្ញាតផ្សេងៗដើម្បីជួយដល់ការដាក់ទណ្ឌកម្មឲ្យនៅតែឯង។
- ចូរដើរតាមធ្វើឲ្យចប់នូវការដាក់ទណ្ឌកម្មឲ្យនៅតែឯងឲ្យបានសប់គ្រប់។
- ចូរឲ្យកុមារទទួលខុសត្រូវក្នុងការសំអាតកន្លែងក្រខ្វក់ចេញនៅពេលទទួលទណ្ឌកម្មឲ្យនៅតែឯង។
- ចូរទ្រទ្រង់ដៃគូរដែលអនុវត្តន៍ការដាក់ទណ្ឌកម្មឲ្យនៅតែឯង។
- ចូរកុំពឹងផ្អែកទាំងស្រុងទៅលើការដាក់ទណ្ឌកម្មឲ្យនៅតែឯងឡើយ- ចូរធ្វើជាមួយបច្ចេកទេសអប់រំផ្សេងៗទៀតដូចជាការធ្វើព្រងើយកន្ដើយ ផលវិបាកដែលសមហេតុសមផល និងការដោះស្រាយបញ្ហា។
- ចូរសង្ឃឹមឲ្យមានការសាកល្បងរៀនជាថ្មីដដែល។
- ចូរដាក់ប្រាក់សន្សំនៅក្នុងកុងធានាគារនៅពេលសរសើរ ស្រឡាញ់ ហើយទ្រទ្រង់។
- ចូរប្រើពេលការដាក់ទណ្ឌកម្មឲ្យនៅតែឯងផ្ទាល់ខ្លួនដើម្បីសម្រាកនិងបំពេញកម្លាំងពលំ។


©Carolyn Webster-Stratton

## ការពិនិត្យជាថ្មីឡើងវិញនិងការដោះស្រាយបញ្ហា "ដាក់វាទាំងអស់ចូលគ្នា"

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

### អ្វីដែលត្រូវធ្វើ:



- ចូរជ្រើសរើសយកបញ្ហាមួយមកពិភាក្សា ជាមួយកូនលោកអ្នកដោយប្រើវិធីដោះស្រាយបញ្ហា។ កត់ការជជែកគ្នាទុកនៅលើសន្លឹកក្រដាសកត់ពីការដោះស្រាយបញ្ហា "Record Sheet: Problem Solving" ដែលគេឲ្យលោកអ្នក។

- ចូរគិត ពីមធ្យោបាយផ្សេងៗដើម្បីបង្រៀនកូនលោកអ្នកពីរបៀបនិយាយស្តីដើម្បីពោលអះអាង។ ការនេះជួយកូនលោកអ្នកចៀសវាងស្ថិតនៅក្នុងស្ថានភាពដែលបណ្តាលឲ្យមានបញ្ហាជាមួយនឹងកូនក្មេងឯទៀត។

## ការអបអរនិងការដើរទៅមុខទៀត!

- ចូរគិតពីវិធានការដើម្បីនៅតែឲ្យមានការទ្រទ្រង់ចំពោះការខិតខំរបស់លោកអ្នកនៅក្នុងការដឹកនាំចិញ្ចឹមកូនចៅ។

- ចូររៀបចំឲ្យមានអ្វីមួយនៅក្នុងខែក្រោយ។



*©Carolyn Webster-Stratton*




## កំណត់សំគាល់សំខាន់ៗ
## អំពីផលវិបាកដែលធម្មតា
## និងសមហេតុសមផល

- ចូរធ្វើឲ្យមានផលវិបាកដែលត្រូវតាមអាយុ។
- ចូរឲ្យបានច្បាស់ថាលោកអ្នកអាចទ្រាំទ្រនឹងផលវិបាកដែលលោកអ្នកបានរៀបចំឡើង។
- ចូរធ្វើឲ្យមានផលវិបាកភ្លាមៗ។
- ចូរឲ្យកូនលោកអ្នកជ្រើសរើសយកផលវិបាកណាមួយឲ្យបានជាមុន។
- ចូរធ្វើឲ្យផលវិបាកនោះធម្មតានិងដែលមិនមែនជាការដាក់ទណ្ឌកម្ម។
- ចូរឲ្យកូនលោកអ្នកចូលរួមនៅពេលណាដែលអាចធ្វើទៅកើត។
- ចូរដាក់ផលវិបាកណាដែលខ្លីហើយចំចំណុច។
- ចូរផ្តល់ឲ្យមានឱកាសសិក្សាថ្មីភ្លាមៗដើម្បីឲ្យមានជោគជ័យ។


*©Carolyn Webster-Stratton*




What is the best solution?

# កំណត់សំគាល់សំខាន់ៗ អំពីការដោះស្រាយបញ្ហា

- ចូរនិយាយពីអារម្មណ៍ផ្សេងៗ។
- ចូរជួយកូនលោកអ្នកឲ្យអត្ថន័យនៃពាក្យបញ្ហា។
- នាំកូនលោកអ្នកឲ្យបានចូលរួមនៅក្នុងការជួយរិះរកចម្លើយផ្សេងៗប្រសិនអាចធ្វើទៅបាន។
- ចូរឲ្យបានពេញទៅដោយការដែលជាទីសង្ឃឹមនិងដែលមានប្រឌិតញាណ។
- ចូរយកចម្លើយដែលពេញទៅដោយការប្រឌិតធ្វើជាគំរូដោយខ្លួនលោកអ្នក។
- ចូរលើកទឹកចិត្តកូនលោកអ្នកឲ្យរៀនគិតឲ្យបានហ្មត់ចត់ពីផលវិបាកផ្សេងៗពីចម្លើយខុសៗគ្នា។
- ចូរចងចាំថាគឺជារបៀបរៀនគិតពីបញ្ហានោះទេដែលសំខាន់ មិនមែនរកចម្លើយផ្សេងៗដែលត្រូវនោះទេ។


*©Carolyn Webster-Stratton*

# សកម្មភាពផ្សេងៗនៅផ្ទះប្រចាំសប្តាហ៍

អ្វីដែលត្រូវធ្វើ: 



©Carolyn Webster-Stratton